**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**

ក្រសួងបរិស្ថាន

លេខៈ ០៤១ ប្រកស.....ប.ស្ត .កអរ

រាជធានីភ្នំពេញ. ថ្ងៃទី...22...ខែ...01.....ឆ្នាំ២០០៣.

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ នៃដែនជំរកសត្វព្រៃបឹងពែរខេត្តកំពង់ធំ–ព្រះវិហារ–សៀមរាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១៩៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីជូនដំណឹង លេខ ២៩៥ សជណ.កស ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្អែកតាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន ដែលស្ថិតនៅក្នុងតំបន់ដែនជំរកសត្វព្រៃបឹងពែរ ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តសៀមរាប

## សំរេច

**ប្រការ១** : រៀបចំសហគមន៍តំបន់ការពារធម្មជាតិ ដែលស្ថិតនៅក្នុងតំបន់ទ្រនាប់នៃដែនជំរកសត្វព្រៃបឹងពែរ ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តសៀមរាប ។

**ប្រការ២** : សហគមន៍តំបន់ការពារធម្មជាតិ នៃដែនជំរកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងឃុំពស្រលើ ស្រុកជីក្រែង ខេត្តសៀមរាប មានផ្ទៃដី ២.៤៤០ហិកតា ដូចបានកំណត់ក្នុងផែនទី ដែលមានភ្ជាប់ជូន និងកូអរដោនេព្រំប្រទល់ដូចខាងក្រោម

| ល.រ | អាប់ស៊ីស X | អរដោនេ Y | ចំណុច | អាប់ស៊ីស X | អរដោនេ Y |
|---|---|---|---|---|---|
| A | 447.839 | 1.465.418 | J | 443.738 | 1.468.977 |
| B | 446.992 | 1.465.299 | K | 443.281 | 1.470.280 |
| C | 446.794 | 1.464.988 | L | 443.262 | 1.470.531 |
| D | 445.980 | 1.464.909 | M | 444.002 | 1.471.563 |
| E | 445.107 | 1.465.081 | N | 445.782 | 1.472.397 |
| F | 444.373 | 1.465.405 | O | 446.410 | 1.472.509 |
| G | 443.906 | 1.466.807 | P | 447.038 | 1.470.412 |
| H | 443.156 | 1.466.741 | Q | 447.363 | 1.467.000 |
| I | 442.699 | 1.468.243 | | | |

**ប្រការ៣** : ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ នៃដែនជម្រកសត្វព្រៃបឹងពែរ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយនឹងក្រសួងបរិស្ថាន ហើយសហគមន៍នេះត្រូវមានលក្ខន្តិកៈដោយឡែក ។

**ប្រការ៤** : អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន នាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ បណ្ដានាយកដ្ឋាន អង្គភាពពាក់ព័ន្ធ មន្ទីរបរិស្ថានខេត្តកំពង់ធំ-ខេត្តព្រះវិហារ-ខេត្តសៀមរាប និងសហគមន៍តំបន់ការពារធម្មជាតិនៃដែនជម្រកសត្វព្រៃបឹងពែរ ឃុំពង្រលើត្រូវសហការអនុវត្តសេចក្ដីប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ចម្លងជូន:*

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- អភិបាលខេត្តកំពង់ធំ
- អភិបាលខេត្តព្រះវិហារ
- អភិបាលខេត្តសៀមរាប
- មន្ទីរបរិស្ថានខេត្តកំពង់ធំ-ព្រះវិហារ-សៀមរាប
- ឯកសារ. កាលប្បវត្តិ

រដ្ឋមន្ត្រី

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា